# សុន្ទរកថា ឯកឧត្តម ឆាយ ថន
# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ
# ក្នុងពិធីផ្សព្វផ្សាយលទ្ធផលបឋមនៃការអង្កេតសាកល្បង
# នៃជំរឿនសហគ្រាសឆ្នាំ ២០១១

មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា ជប៉ុន, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០

**សូមគោរព:** - គណៈអធិបតី

- ឯកឧត្តមតំណាងស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- លោក **យ៉ាសូជីរ៉ូ ស៊ូស៊ុយគី** តំណាងអង្គការ JICA ប្រចាំនៅកម្ពុជា
- ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការក្រសួងផែនការ
- លោក F. Nishi ប្រធានទីប្រឹក្សា និង ជំនាញការ JICA
- លោក លោកស្រីតំណាងអង្គការជាតិ និង អន្តរជាតិ
- លោក លោកស្រីអ្នកចូលរួមទាំងអស់

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសដោយបានចូលរួមក្នុងពិធីផ្សព្វផ្សាយលទ្ធផលបឋមនៃការអង្កេតសហគ្រាសសាកល្បងនៃជំរឿនសហគ្រាសឆ្នាំ ២០១១ និង សូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានមកចូលរួមក្នុងពិធីនេះ ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ក្នុងនាមក្រសួងផែនការ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតំលៃខ្ពស់ចំពោះរដ្ឋាភិបាលជប៉ុន និងអង្គការJICA សំរាប់ការឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុតាមរយៈគំរោងពង្រឹងស្ថិតិផ្លូវការនៅកម្ពុជា ក្នុងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ និងបានធ្វើអង្កេតសាកល្បង នៅខែមីនា ឆ្នាំ ២០១០កន្លងមកនេះដោយជោគជ័យ ។

**ឯកឧត្តម លោកជំទាវ**

**លោក លោកស្រី**

ដោយថវិការាជរដ្ឋាភិបាលកម្ពុជាមានកំរិត វិទ្យាស្ថានជាតិស្ថិតិបានឈប់ធ្វើអង្កេតសហគ្រាស តាំងពីគំរោងធនាគារអភិវឌ្ឍន៍អាស៊ីបានបញ្ចប់នៅឆ្នាំ ២០០៣ ។

បន្ទាប់ពីគំរោងធនាគារអាស៊ីបានបញ្ចប់ វិទ្យាស្ថានជាតិស្ថិតិ បានទទួលការឧបត្ថម្ភពី JICA សំរាប់ការធ្វើអង្កេតសហគ្រាសនៅខេត្តមួយចំនួន និងធ្វើបញ្ជីសហគ្រាសទូទាំងប្រទេសកម្ពុជានៅឆ្នាំ ២០០៩ និងការរៀបចំជំរឿនសហគ្រាសឆ្នាំ ២០១១ ស្របទៅតាមផែនការមេស្ថិតិ ឆ្នាំ ២០០៨-២០១៥ ។

តាមការឧបត្ថម្ភរបស់ JICA និងរដ្ឋាភិបាលជប៉ុន វិទ្យាស្ថានជាតិស្ថិតិបានធ្វើអង្កេតសាកល្បងនៃជំរឿនសហគ្រាសឆ្នាំ ២០១១ ដែលបានចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មីនារហូតដល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១០ កន្លងមកនេះ ។

នេះជាការអង្កេតសគ្រាសថ្នាក់ជាតិបានធ្វើឡើងដោយរាប់សហគ្រាសទាំងអស់នៅក្នុងភូមិជ្រើសគំរូ លើកលែងតែសហគ្រាសកសិកម្ម រុក្ខកម្ម និងនេសាទ និងសហគ្រាសចល័ត។ ការង្កេតនេះបានគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដោយរដ្ឋាភិបាលជប៉ុន និងអង្គការ JICA តាមរយៈគំរោងពង្រឹងស្ថិតិផ្លូវការនៅកម្ពុជាជំហានទី២។ យើងកំពុងផលិតទិន្នន័យផ្លូវការ និងផ្សព្វផ្សាយលទ្ធផលថ្ងៃនេះ ។

ការអង្កេតសាកល្បងនេះ គឺសំខាន់ក្នុងការផ្តល់ទិន្នន័យសំរាប់ការចងក្រងគណនេយ្យជាតិ សូចនាករសំខាន់ៗ ដែលអនុញ្ញាតអោយយើងដឹងពីស្ថានភាពសេដ្ឋកិច្ច។ តាមរយៈលទ្ធផលទាំងនេះ យើងអាចផលិតតារាងស្ថិតិ ដូចជាចំនួនសរុបសហគ្រាស ចំនួនកម្មករតាមសកម្មភាពសេដ្ឋកិច្ច លក្ខណៈនៃអ្នកតំណាងសហគ្រាស ភាពជាកម្មសិទ្ធ ប្រភេទ និងផ្ទៃក្រឡានៃទីកន្លែងអាជីវកម្ម ប្រភេទសកម្មភាពអាជីវកម្ម តារាងតុល្យការ និងរបាយការណ៍ចំណូល ។ល។ តាមរយៈសកម្មភាពទាំងនេះ យើងអាចពង្រឹងចំណេះដឹង ជំនាញ និងសមត្ថភាពមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីរាជធានី ខេត្ត ដើម្បីគាំទ្រជំរឿនសហគ្រាសនៅឆ្នាំ ២០១១នេះ ។

ជាទូទៅលទ្ធផលនៃការអង្កេតសាកល្បងនេះនឹងផ្តល់ព័ត៌មានពីសកម្មភាពសេដ្ឋកិច្ចបច្ចុប្បន្ននៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាតំរូវការទូទៅនៃទិន្នន័យ ដូចជាអ្នកធ្វើគោលនយោបាយ អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន អ្នកស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍ដ៏ទៃទៀត និង ជាពិសេសការអង្កេតផ្តល់នូវមូលដ្ឋានទិន្នន័យ សំរាប់ផែនការជំរឿនសហគ្រាសឆ្នាំ ២០១១ ។

ខ្ញុំសូមជំរាបជូនពីលទ្ធផលបឋមនៃការអង្កេតសហគ្រាសសាកល្បង ខែមីនា ឆ្នាំ២០១១ ដូចតទៅ : នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១០ សហគ្រាសសរុបមាន ចំនួន ៥៣៣,៥១៥ សហគ្រាស។ ចំនួនមនុស្សធ្វើការនៅតាមសហគ្រាសទាំងនោះមាន ១.៨២០,៣៤២ ដែលក្នុងនោះបុរសមាន ៧៦១,១០៩ នាក់ ឬ ៤១.៨ % និងស្ត្រីមាន ១,០៥៩,២៣៤ នាក់ ឬ ៥៨.២ % ចំនួនស្ត្រីមានច្រើនជាងបុរស។

ប្រៀបធៀបទៅនឹងលទ្ធផលនៃការធ្វើបញ្ជីសហគ្រាសឆ្នាំ ២០០៩ ចំនួនមនុស្សធ្វើការបានកើនឡើង ១៥.៧ % ហើយការប៉ាន់ស្មានកំណើនប្រចាំឆ្នាំស្មើនឹង ១៤.៥ % ។ ដោយអត្រាកំណើនប្រជាជនស្មើ ១.៥៤ % អត្រាកំណើនមនុស្សធ្វើការមានកំណើនខ្ពស់ណាស់។ នេះបង្ហាញអោយឃើញថាចំនួនមនុស្ស ដែលធ្វើការនៅវិស័យទីមួយបានផ្លាស់ទៅ វិស័យទីពីរ ឬទីបី។ នេះជាអភិក្រមធម្មតានៅក្នុងកិច្ចអភិវឌ្ឍន៍ ដែលគេសង្កេតឃើញនៅគ្រប់ប្រទេសកំពុងអភិវឌ្ឍន៍។

ចំណូលសរុបពីការលក់របស់សហគ្រាសនៅកម្ពុជាស្មើ ១៤.៣ ពាន់ដុល្លារ ។ ក្នុងនោះសហគ្រាសដែលមានកម្មករពី ១០០ នាក់ឡើងទៅមានសមាមាត្រក្នុងចំណូលសរុបខ្ពស់ជាងគេបំផុតគឺ ៤.២ ពាន់លានដុល្លារ ត្រូវជា ២៩.០ % ។ បន្ទាប់មកសហគ្រាសដែលមានកម្មករពី ៥០ ទៅ ៩៩ នាក់ មានសមាមាត្រ ១៧.៥ % ហើយសហគ្រាសមានកម្មករពី ១០ ទៅ ៤៩ នាក់មានសមាមាត្រតែ ១០.២ % ប៉ុណ្ណោះ ។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តគោលនយោបាយជំរុញការបង្កើត និងការកំណើនសហគ្រាសមធ្យម ។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានមកចូលរួមពិធីផ្សព្វផ្សាយនេះ ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តមតំណាងស្ថានទូតជប៉ុន តំណាងអង្គការ JICA ប្រចាំកម្ពុជា ប្រធានទីប្រឹក្សា អ្នកជំនាញការ JICA និង រដ្ឋាភិបាលជប៉ុន ដែលបានគាំទ្រប្រព័ន្ធស្ថិតិកម្ពុជារួមទាំង ការអង្កេតសាកល្បង និង ជំរឿនសហគ្រាសឆ្នាំ ២០១១ ។ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី នូវពុទ្ធពរទាំងបួន ប្រការ និង ទទួលបានជោគជ័យគ្រប់ភារៈកិច្ច ។

ខ្ញុំសូមប្រកាសផ្សព្វផ្សាយជាផ្លូវការលទ្ធផលបឋមអង្កេតសាកល្បងឆ្នាំ ២០១០ ចាប់ពីពេលនេះតទៅ ។

***សូមអរគុណ!***